# កាលប្បវត្តិព្រឹត្តិការណ៍៖ មួយឆ្នាំចាប់តាំងពីការចាប់ខ្លួនលោក រ៉ុង ឈុន



## តើលោក រ៉ុង ឈុន ជានរណា?

លោកគឺជាមេដឹកនាំសហជីព និងជាសកម្មជនលេចធ្លោមួយរូប។ លោកគឺជាប្រធានសហព័ន្ធសហជីពឯករាជ្យកម្ពុជា ជាអតីតប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ និងជាសមាជិកក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា។

## តើអ្វីទៅជាបទញុះញង់?

ជាបទល្មើសព្រហ្មទណ្ឌ ដែលមានចែងក្នុងមាត្រា៤៩៤ និង៤៩៥ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាគឺ «បទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍»។ បទចោទនេះអាចផ្ដន្ទាទោសដាក់ពន្ធនាគារពីប្រាំមួយខែទៅពីរឆ្នាំ។

→ បទញុះញង់នេះជារឿយៗត្រូវបានប្រើទៅលើសកម្មជន និងអ្នកការពារសិទ្ធិមនុស្សដោយសារតែការអនុវត្តសិទ្ធិរបស់ពួកគេ។

## ខែកក្កដា ឆ្នាំ២០២០

**ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០** – លោក រ៉ុង ឈុន បានធ្វើទស្សនកិច្ចនៅតំបន់ជាប់ព្រំដែនវៀតណាមស្ថិតក្នុងខេត្តត្បូងឃ្មុំ ជាតំបន់ដែលកសិករត្រូវបានរារាំងមិនឱ្យដាំដុះលើដីរបស់ពួកគេ ដោយសារតែការបោះបង្គោលព្រំដែនថ្មី។ បន្ទាប់ពីទស្សនកិច្ចនោះ គាត់បានចេញសេចក្តីថ្លែងការណ៍មួយក្នុងនាមជាក្រុមប្រឹក្សាឃ្លាំមើលកម្ពុជាអំពីភាពមិនប្រក្រតីនៃបង្គោលព្រំដែនថា ការបោះបង្គោលនោះធ្វើឱ្យបាត់បង់ដីស្រែរបស់កសិករកម្ពុជាជាច្រើនហិកតា។ ការអះអាងនេះត្រូវបានគណៈកម្មាធិការកិច្ចការព្រំដែនរបស់រដ្ឋាភិបាលច្រានចោល ហើយលោក រ៉ុង ឈុន ត្រូវបានចោទប្រកាន់ថាបានផ្សព្វផ្សាយព័ត៌មានមិនពិត។



**ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០** – លោក រ៉ុង ឈុន បានផ្តល់បទសម្ភាសន៍ជាមួយវិទ្យុអាស៊ីសេរី ដោយលោកបានច្រានចោលថាលោកមិនបានផ្សព្វផ្សាយព័ត៌មានមិនពិតអំពីការបាត់បង់ដីធ្លីនៅតាមព្រំដែននោះទេ។ ប៉ុន្មានម៉ោងក្រោយមកនាយប់នោះ មន្ត្រីប្រដាប់អាវុធប្រមាណ៥០នាក់បានហ៊ុំព័ទ្ធផ្ទះរបស់គាត់ និងត្រូវបានចាប់ខ្លួនដោយគ្មានដីកាពីតុលាការ។

## ខែសីហា ឆ្នាំ២០២០

**ថ្ងៃទី០១ ខែសីហា ឆ្នាំ២០២០** – លោក រ៉ុង ឈុន ត្រូវបានចោទប្រកាន់ពីបទញុះញង់។ មូលហេតុនៃការចាប់ខ្លួនគឺពាក់ព័ន្ធទៅនឹងការអត្ថាធិប្បាយរិះគន់របស់គាត់លើការបោះបង្គោលព្រំដែនរវាងកម្ពុជា និងវៀតណាម។ លោក រ៉ុង ឈុន ត្រូវបានបញ្ជូនទៅឃុំខ្លួនបណ្តោះអាសន្ន។

**ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០** – សាលាឧទ្ធរណ៍បានបដិសេធដោះលែងលោក រ៉ុង ឈុន ឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ដោយលើកឡើងពីគ្រោះថ្នាក់ដែលអាចកើតឡើងថាគាត់នឹងចេញសេចក្តីថ្លែងការណ៍ម្តងទៀត។

## ខែវិច្ឆិកា ឆ្នាំ២០២០

**ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០** – លោក រ៉ុង ឈុន បានផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការកំពូលថាការឃុំខ្លួនគាត់គឺមិនស្របច្បាប់ និងបានដាក់សំណើសុំនៅក្រៅឃុំម្តងទៀតដើម្បីបដិសេធការឃុំខ្លួនរបស់គាត់។ គាត់បានសន្យាថានឹងសហការជាមួយតុលាការ និងអាជ្ញាធរ ប្រសិនបើពួកគេត្រូវការឱ្យគាត់ធ្វើសក្ខីកម្មនៅថ្ងៃក្រោយ។



**ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០** – តុលាការកំពូលបានបដិសេធសំណើសុំនៅក្រៅឃុំរបស់លោក រ៉ុង ឈុន ក្រោមហេតុផលការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសន្តិភាពរបស់ប្រទេស។

## ខែមករា ឆ្នាំ២០២១

**ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២១** – សាលាដំបូងរាជធានីភ្នំពេញបានចាប់ផ្តើមសវនាការជំនុំជម្រះចំពោះការចោទប្រកាន់ពីបទញុះញង់លើលោក រ៉ុង ឈុន។ សវនាការនេះមានរយៈពេលបីម៉ោង។ លោកបានបដិសេធចំពោះការចោទប្រកាន់ថាបានញុះញង់ពលរដ្ឋតាមរយៈការអត្ថាធិប្បាយរបស់គាត់ទាក់ទងនឹងបញ្ហាព្រំដែនកម្ពុជាវៀតណាម ហើយអះអាងថាលោកកំពុងអនុវត្តសេរីភាពខាងការបញ្ចេញមតិរបស់លោកដើម្បីនិយាយពីបញ្ហាសំខាន់។

## ខែកុម្ភៈ ឆ្នាំ២០២១

**ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១** – សាលាដំបូងរាជធានីភ្នំពេញបានបន្តការពិភាក្សាដេញដោលបន្ថែមទៀតលើករណីលោក រ៉ុង ឈុន។ លោក រ៉ុង ឈុន បានបញ្ជាក់ថាលោកទើបតែបានចុះទៅខេត្តត្បូងឃ្មុំកាលពីខែកក្កដា ឆ្នាំ២០២០ ដើម្បីជួយដល់អ្នកភូមិដែលរងផលប៉ះពាល់ ហើយលោកមិនបានចុះត្រួតពិនិត្យតំបន់ព្រំដែនទេ ប៉ុន្តែលោកបានចុះទៅឃ្លាំមើលជម្លោះដីធ្លីដែលកើតឡើងនៅតាមព្រំដែន។ លោកបានបន្តទៀតថាការអត្ថាធិប្បាយរបស់លោកមិនមែនជាការរិះគន់ដល់រដ្ឋាភិបាលទេ គ្រាន់តែជាអង្គហេតុប៉ុណ្ណោះ។

**ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១** – ក្នុងសវនាការនេះ លោករ៉ុង ឈុនបានបដិសេធការចោទប្រកាន់រូបលោកពីបទញុះញង់ និងបានអះអាងបន្ថែមទៀតថានគរបាលបានប្រើនីតិវិធីមិនត្រឹមត្រូវដើម្បីចាប់ខ្លួនគាត់ ពោលគឺមិនមានដីកាផ្លូវការពីតុលាការ។

## ខែមិថុនា ឆ្នាំ២០២១



**ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២១** – បន្ទាប់ពីចំណាយពេលជាង១១ខែ ក្នុងពន្ធនាគារ លោក រ៉ុង ឈុន ត្រូវបានបដិសេធសំណើសុំនៅក្រៅឃុំ ទោះបីមានការផ្ទុះឡើងជំងឺកូវីដ១៩ នៅក្នុងពន្ធនាគារកម្ពុជាក៏ដោយ។ គាត់បានជាប់ពន្ធនាគារស្ទើរតែពាក់កណ្តាលនៃទោសអតិបរមានៃបទញុះញង់ ដែលបញ្ញត្តិទោសជាប់ពន្ធនាគារអតិបរមារយៈពេលពីរឆ្នាំ។ គាត់មិនមានវត្តមាននៅក្នុងសវនាការនោះទេ។

## ខែកក្កដា ឆ្នាំ២០២១

**ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១** – សាលាដំបូងរាជធានីភ្នំពេញបានបន្តសវនាការករណីលោក រ៉ុង ឈុន។ សាក្សីតំណាងឱ្យនាយកដ្ឋានដោះស្រាយបាតុភាពតាមព្រំដែនបានធ្វើការបញ្ជាក់បន្ថែមលើករណីនេះ។ តុលាការគ្រោងប្រកាសសាលក្រមនៅក្នុងខែសីហា ឆ្នាំ២០២១។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights
@CCHRCambodia
cchrcambodia.org
@CCHRCambodia
sithi.org

CC BY NC SA

ខែកក្កដា ឆ្នាំ២០២១

# កាលប្បវត្តិនៃការចាប់ខ្លួនសកម្មជនដោយសារតែការតវ៉ា ឱ្យដោះលែងលោក រ៉ុង ឈុន



ការចាប់ខ្លួនលោក រ៉ុង ឈុន បានបង្កជាការតវ៉ានៅក្នុងប្រទេស ដោយមានការប្រមូលផ្តុំរបស់ក្រុមយុវជនអំពាវនាវឱ្យមានការដោះលែងលោក រ៉ុង ឈុន។ ជាលទ្ធផល ក្រុមអ្នកតវ៉ាត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទញុះញង់។

**តើអ្វីទៅជាបទញុះញង់?**

ជាបទល្មើសព្រហ្មទណ្ឌ ដែលមានចែងក្នុងមាត្រា៤៩៤ និង៤៩៥ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាគឺ «បទញុះញង់ឱ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍»។ បទចោទនេះអាចផ្តន្ទាទោសដាក់ពន្ធនាគារពីប្រាំមួយខែទៅពីរឆ្នាំ។

→ បទញុះញង់នេះជារឿយៗត្រូវបានប្រើទៅលើសកម្មជន និងអ្នកការពារសិទ្ធិមនុស្សដោយសារតែការអនុវត្តសិទ្ធិរបស់ពួកគេ។







## ខែសីហា ឆ្នាំ២០២០

**ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០ - ចាប់ខ្លួនអតីតសកម្មជនគណបក្សសង្គ្រោះជាតិ**
បន្ទាប់ពីចូលរួមតវ៉ាទាមទារឱ្យដោះលែងលោក រ៉ុង ឈុន សកម្មជនពីរនាក់មកពីអតីតគណបក្សប្រឆាំង លោក ឈួរ ផេង និងលោក ជុំ ពុទ្ធី ត្រូវបានចាប់ខ្លួននៅភ្នំពេញ។ សកម្មជនទាំងនោះបានព្យាយាមជួបជាមួយព្រះសង្ឃដែលបាននិមន្តពីខេត្តបាត់ដំបងដើម្បីចូលរួមតវ៉ានៅរាជធានីភ្នំពេញ ប៉ុន្តែត្រូវបានអាជ្ញាធរបញ្ឈប់នៅតាមផ្លូវ។ ក្រោយមកអ្នកទាំងពីរត្រូវបានចោទប្រកាន់ពីបទញុះញង់។

**ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០ - ការចាប់ខ្លួនកញ្ញា ស កណិការ**
អតីតសកម្មជនគណបក្សសង្គ្រោះជាតិម្នាក់ទៀតគឺកញ្ញា ស កណិការ ត្រូវបានចាប់ខ្លួនបន្ទាប់ពីចូលរួមតវ៉ាទាមទារឱ្យមានការដោះលែងលោក រ៉ុង ឈុន។ ក្រោយមកកញ្ញាត្រូវបានចោទប្រកាន់ពីបទញុះញង់ និងបញ្ជូនទៅឃុំខ្លួនបណ្តោះអាសន្ន។

**ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ - ការចាប់ខ្លួនកញ្ញា ឈឿន ដារ៉ាវី និងលោក ហ៊ុន វណ្ណៈ** - សកម្មជនពីរនាក់នៃក្រុមយុវជនខ្មែរថាវរៈ លោក ហ៊ុន វណ្ណៈ និងកញ្ញា ឈឿន ដារ៉ាវី ដែលបានប្រមូលផ្តុំគ្នានៅមុខសាលាដំបូងរាជធានីភ្នំពេញដើម្បីទាមទារឱ្យមានការដោះលែងលោក រ៉ុង ឈុន ត្រូវបានចាប់ខ្លួន។ ពួកគេត្រូវបានឃុំខ្លួន និងចោទប្រកាន់ពីបទញុះញង់មួយថ្ងៃក្រោយមក។

**ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ - ការចាប់ខ្លួនលោក សួង សុភ័ណ្ឌ** - លោក សួង សុភ័ណ្ឌ ប្រធានគណបក្សខ្មែរឈ្នះត្រូវបានចាប់ខ្លួនបន្ទាប់ពីធ្វើទស្សនកិច្ចនៅខេត្តត្បូងឃ្មុំដើម្បីមើលតំបន់មានជម្លោះព្រំដែនកម្ពុជា វៀតណាម ដែលលោក រ៉ុង ឈុនបានធ្វើទស្សនកិច្ច ហើយក្រោយមកលោកបានបង្ហោះវីដេអូនៅលើហ្វេសប៊ុកនិយាយពីភាពមិនប្រក្រតីនៃព្រំដែននេះ។ លោក សួង សុភ័ណ្ឌ ក៏បានចូលរួមតវ៉ាទាមទារឱ្យដោះលែងលោក រ៉ុង ឈុន ផងដែរ។ អាជ្ញាធរអះអាងថាព័ត៌មានដែលគាត់បានផ្សព្វផ្សាយអំពីបញ្ហាព្រំដែនគឺជាការញុះញង់។ នៅថ្ងៃបន្ទាប់គាត់ត្រូវបានចោទប្រកាន់ពីបទញុះញង់។

## ខែកញ្ញា ឆ្នាំ២០២០

ស កណិការ



**ថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០ - ការបដិសេធសំណើសុំនៅក្រៅឃុំបណ្តោះអាសន្នរបស់កញ្ញា ស កណិការ** - សំណើសុំនៅក្រៅឃុំបណ្តោះអាសន្នរបស់កញ្ញា ស កណិការ ត្រូវបានបដិសេធដោយសាលាដំបូងរាជធានីភ្នំពេញ។

**ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២០ - ការចាប់ខ្លួនព្រះតេជគុណ កើត សារ៉ាយ និងលោក មាន ព្រហ្មមុនី** - ព្រះតេជគុណ កើត សារ៉ាយ គឺជាព្រះសង្ឃមួយអង្គ និងជាសមាជិកក្រុមខ្មែរថាវរៈ និងលោក មាន ព្រហ្មមុនី អនុប្រធានសមាគមនិស្សិតបញ្ញវន្តខ្មែរ ត្រូវបានចាប់ខ្លួនដោយសារការរៀបចំការជួបជុំដោយសន្តិវិធីដើម្បីទាមទារឱ្យដោះលែងលោក រ៉ុង ឈុន។ នៅថ្ងៃបន្ទាប់ អ្នកទាំងពីរត្រូវបានចោទប្រកាន់ពីបទញុះញង់ និងបញ្ជូនទៅឃុំខ្លួនបណ្តោះអាសន្ន។ ព្រះតេជគុណ កើត សារ៉ាយ ក៏ត្រូវបានផ្សឹកផងដែរ។

**ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ - ការចាប់ខ្លួនលោក ថា ឡាវី និងកញ្ញា សូ មេត្តា ឬកញ្ញា អេង ម៉ាឡៃ** - សមាជិកខ្មែរថាវរៈ លោក ថា ឡាវី និងកញ្ញា សូ មេត្តា (ឬកញ្ញា អេង ម៉ាឡៃ) ត្រូវបានចាប់ខ្លួនដោយសារតែទាមទារឱ្យដោះលែងលោក រ៉ុង ឈុន។ លោក ថា ឡាវី ត្រូវបានចាប់ខ្លួនខណៈដែលលោកកំពុងចុះពីម៉ូតូកង់បីនៅឯទីលានប្រជាធិបតេយ្យក្នុងក្រុងភ្នំពេញដើម្បីចូលរួមបាតុកម្មដោយសន្តិវិធីទាមទារឱ្យដោះលែងលោក រ៉ុង ឈុន។ កញ្ញា អេង ម៉ាឡៃ ត្រូវបានចាប់ខ្លួនដោយអាជ្ញាធរបន្ទាប់ពីគាត់កំពុងចាកចេញពីការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ជាកន្លែងដែលគាត់បានលើកឡើងពីការព្រួយបារម្ភអំពីសន្តិសុខដែលអាជ្ញាធរកំពុងតាមគាត់បន្ទាប់ពីគាត់បានចាកចេញពីការតវ៉ានៅទីលានប្រជាធិបតេយ្យ។ ក្រោយមកពួកគេត្រូវបានចោទប្រកាន់ពីបទញុះញង់។

**ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០ - ការចាប់ខ្លួនលោក មួង សុភ័ក្រ្ត** - លោក មួង សុភ័ក្រ្ត គឺជាសមាជិកសមាគមនិស្សិតបញ្ញវន្តខ្មែរត្រូវបានចាប់ខ្លួនដោយសារតែការចូលរួមរបស់គាត់ក្នុងការតវ៉ាដោយសន្តិវិធីមួយទាមទារឱ្យដោះលែងលោក រ៉ុង ឈុន កាលពីប៉ុន្មានថ្ងៃមុន។ នៅថ្ងៃបន្ទាប់លោកត្រូវបានចោទប្រកាន់ពីបទញុះញង់។

មួង សុភ័ក្រ្ត



## ខែតុលា ឆ្នាំ២០២០

**ថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០ - សាលាឧទ្ធរណ៍ច្រានចោលសំណើសុំនៅក្រៅឃុំរបស់កញ្ញា ស កណិការ**
សាលាឧទ្ធរណ៍បានតម្កល់សេចក្តីសម្រេចរបស់សាលាដំបូងរាជធានីភ្នំពេញកាលពីថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០ ដោយបដិសេធសំណើសុំនៅក្រៅឃុំបណ្តោះអាសន្នរបស់កញ្ញា ស កណិការ។



ហ៊ុន វណ្ណៈ

ឈឿន ដារ៉ាវី



**ថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ - សាលាឧទ្ធរណ៍បដិសេធសំណើសុំនៅក្រៅឃុំរបស់លោក ហ៊ុន វណ្ណៈ និងកញ្ញា ឈឿន ដារ៉ាវី** - សាលាឧទ្ធរណ៍បានច្រានចោលសំណើសុំនៅក្រៅឃុំរបស់លោក ហ៊ុន វណ្ណៈ និងកញ្ញា ឈឿន ដារ៉ាវី។ តុលាការបានសំអាងថាការច្រានចោលនេះចាំបាច់សម្រាប់ការស៊ើបអង្កេតបន្ថែមទៀតលើករណីរបស់ពួកគេ និងរារាំងអ្នកទាំងពីរមិនឱ្យប្រព្រឹត្តបទល្មើសបន្ថែមទៀត។

## ខែធ្នូ ឆ្នាំ២០២០





អេង ម៉ាឡៃ

**ថ្ងៃទី០២ ដល់០៦ ខែធ្នូ ឆ្នាំ២០២០ – អំពើហិង្សានៅក្នុងពន្ធនាគារលើកញ្ញា អេង ម៉ាឡៃ និងកញ្ញា ឈឿន ដារ៉ាវី**
កញ្ញា អេង ម៉ាឡៃ និងកញ្ញា ឈឿន ដារ៉ាវី រងការវាយដំដោយអ្នកជាប់ឃុំផ្សេងទៀតដោយសារតែធ្វើកូដកម្មអត់អាហារចាប់ពីថ្ងៃទី០២ ដល់ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០២០ ដើម្បីស្នើសុំឱ្យមន្ត្រីពន្ធនាគារគោរពសិទ្ធិអ្នកជាប់ឃុំរឿងនយោបាយ។ នាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃបានច្រានចោលការចោទប្រកាន់នេះ ហើយក្រុមមន្ត្រីបញ្ជាក់ថាកញ្ញា អេង ម៉ាឡៃ ធ្វើមិនត្រឹមត្រូវ ហើយថាអ្នកទោសផ្សេងទៀតគ្រាន់តែព្យាយាមនាំនាងចូលក្នុងបន្ទប់ឃុំឃាំងប៉ុណ្ណោះ ចំណែកកញ្ញា ឈឿន ដារ៉ាវី មិនជាប់ពាក់ព័ន្ធនឹងហេតុការណ៍នេះទេ។

**ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ – ការបដិសេធសំណើឱ្យបញ្ចប់ការស៊ើបអង្កេតទៅលើករណីសមាជិកខ្មែរថាវរៈ** – សាលាឧទ្ធរណ៍បានបដិសេធសំណើសុំឱ្យបិទការស៊ើបអង្កេតលើករណីក្រុមយុវជនខ្មែរថាវរៈទាំងប្រាំពីរនាក់ ដោយសំអាងលើការដាក់បណ្តឹងមិនត្រឹមត្រូវទាក់ទងនឹងសំណើនេះ។



មាន ព្រហ្មមុនី

**ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ – សាលាឧទ្ធរណ៍ច្រានចោលសំណើសុំនៅក្រៅឃុំរបស់សមាជិកខ្មែរថាវរៈ និងសមាគមនិស្សិតបញ្ញវន្តខ្មែរ** – សកម្មជនចំនួនប្រាំនាក់រួមមានកញ្ញា អេង ម៉ាឡៃ ព្រះតេជគុណ កើត សារ៉ាយ និងលោក ថា ឡាវី សមាជិកខ្មែរថាវរៈ លោក មាន ព្រហ្មមុនី និងលោក មួង សុភ័ក្រ្ត សមាជិកសមាគមនិស្សិតបញ្ញវន្តខ្មែរ ត្រូវបានសាលាឧទ្ធរណ៍ច្រានចោលសំណើសុំនៅក្រៅឃុំបណ្តោះអាសន្ន ដោយអះអាងថាដើម្បីធានាពីវត្តមានជនជាប់ចោទក្នុងសវនាការរបស់ពួកគេនាពេលខាងមុខ។

**ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ – ការលើកពេលសវនាការករណីក្រុមយុវជន** – សវនាការជំនុំជម្រះករណីសកម្មជនយុវជន និងអតីតសមាជិកគណបក្សសង្គ្រោះជាតិជុំវិញការចូលរួមតវ៉ាទាមទារឱ្យដោះលែងលោក រ៉ុង ឈុន ត្រូវបានលើកពេលដើម្បីកោះហៅមន្ត្រីនគរបាលមួយចំនួនមកផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃសក្ខីកម្មដែលលោក ឈួរ ផេង អតីតសកម្មជនគណបក្សសង្គ្រោះជាតិបានលើកឡើង។ លោក ឈួរ ផេង បានអះអាងថាផ្នែកខ្លះនៃសក្ខីកម្មរបស់លោកគឺជាការពិត តែផ្នែកខ្លះទៀតត្រូវបានប្រឌិតឡើង។

## ខែមករា ឆ្នាំ២០២១

**ថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ – សវនាការសុំនៅក្រៅឃុំរបស់របស់កញ្ញា ស កណិការ នៅតុលាការកំពូល** – តុលាការកំពូលបើកសវនាការសុំនៅក្រៅឃុំបណ្តោះអាសន្នរបស់កញ្ញា ស កណិការ ដែលកំពុងរងចាំការជំនុំជម្រះលើបទញុះញង់។



**ថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ – តុលាការកំពូលច្រានចោលសំណើសុំនៅក្រៅឃុំរបស់កញ្ញា ស កណិការ** – តុលាការកំពូលច្រានចោលសំណើសុំនៅក្រៅឃុំបណ្តោះអាសន្នរបស់កញ្ញា ស កណ្ណិការ។

## ខែកុម្ភៈ ឆ្នាំ២០២១

**ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ – ការបន្តសវនាការករណីកញ្ញា ស កណិការ** – សាលាដំបូងរាជធានីភ្នំពេញបានបើកសវនាការពិភាក្សាបន្ថែមទៀតលើករណីរបស់កញ្ញា ស កណិការ។ គាត់ត្រូវបានសួរយ៉ាងច្រើនអំពីទំនាក់ទំនងរបស់គាត់ជាមួយលោក រ៉ុង ឈុន។



សួង សុភ័ណ្ឌ

**ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១ – ការផ្តន្ទាទោសដាក់ពន្ធនាគារលោក សួង សុភ័ណ្ឌ** – លោក សួង សុភ័ណ្ឌ ប្រធានគណបក្សខ្មែរឈ្នះ ត្រូវបានសាលាដំបូងរាជធានីភ្នំពេញផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល១៨ខែ និងពិន័យជាប្រាក់ចំនួនជាង៥០០,០០០ដុល្លា។ លោក សួង សុភ័ណ្ឌ ត្រូវបានរកឃើញថាមានពិរុទ្ធពីបទញុះញង់ ដោយបំភ្លៃការពិតអំពីបញ្ហាព្រំដែនកម្ពុជា វៀតណាម។

**ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២១ – ការបន្តសវនាការលើក្រុមយុវជន** – សាលាដំបូងរាជធានីភ្នំពេញបានបន្តបើកសវនាការលើករណីសមាជិកខ្មែរថាវរៈ សមាគមនិស្សិតបញ្ញវន្តខ្មែរ និងសកម្មជនគណបក្សសង្គ្រោះជាតិ។ សកម្មជនបួននាក់ ក្នុងចំណោមដប់នាក់ត្រូវបានពិភាក្សាដេញដោល។ តុលាការគ្រោងនឹងបន្តការសវនាការករណីនេះនៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០២១។ សវនាការត្រូវបានលើកពេល។

**ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ – ការបន្តសវនាការករណីកញ្ញា ស កណិការ** – កញ្ញា ស កណិការ បានច្រានចោលការចោទប្រកាន់ពីបទញុះញង់ប្រឆាំងនឹងគាត់ និងបានអះអាងថានគរបាលបានក្លែងបន្លំ និងកែសម្រួលការទាក់ទងរបស់គាត់ជាមួយនឹងមិត្តភក្រ្តម្នាក់ទៀតដើម្បីធ្វើឱ្យគាត់ហាក់ដូចជាមានកំហុសពីបទញុះញង់។

## ខែឧសភា ឆ្នាំ២០២១



**ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១ – ការច្រានចោលសំណើសុំនៅក្រៅឃុំរបស់ក្រុមយុវជនខ្មែរថាវរៈ និងសមាគមនិស្សិតបញ្ញវន្តខ្មែរ** – បន្ទាប់ពីចំណាយពេលជាងប្រាំបីខែក្នុងពន្ធនាគារ សាលាដំបូងរាជធានីភ្នំពេញបានច្រានចោលសំណើសុំនៅក្រៅឃុំបណ្តោះអាសន្នរបស់សកម្មជនចំនួនប្រាំពីរនាក់រួមមានសមាជិកចំនួន០៥នាក់របស់ខ្មែរថាវរៈគឺកញ្ញា ឈឿន ដារ៉ាវី លោក ហ៊ុន វណ្ណៈ ព្រះតេជគុណ កើត សារ៉ាយ លោក ថា ឡាវី កញ្ញា អេង ម៉ាឡៃ និងសមាជិកពីរនាក់នៃសមាគមនិស្សិតបញ្ញវន្តខ្មែររួមមានលោក មួង សុភ័ក្រ្ត និងលោក មាន ព្រហ្មមុនី។ ហេតុផលរបស់តុលាការក្នុងការច្រានចោលសំណើសុំនៅក្រៅឃុំបណ្តោះអាសន្ននោះគឺដើម្បីធានាពីវត្តមានរបស់សកម្មជនក្នុងសវនាការរបស់ពួកគេដែលមិនទាន់ត្រូវបានកំណត់ពេលវេលានៅឡើយ។ សកម្មជនទាំងនោះនៅតែជាប់ឃុំបណ្តោះអាសន្ន។

## ខែមិថុនា ឆ្នាំ២០២១

**ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២១ – ការច្រានចោលសំណើសុំនៅក្រៅឃុំករណីកញ្ញា ស កណិការ**
បន្ទាប់ពីជាប់ឃុំជាង១១ខែ កញ្ញា ស កណិការ ត្រូវបានច្រានចោលសំណើសុំនៅក្រៅឃុំបណ្តោះអាសន្ន ទោះបីមានការរីករាលដាលជំងឺកូវីដ១៩ មិនធ្លាប់មានពីមុនមកនៅក្នុងពន្ធនាគារក៏ដោយ។ កញ្ញា ស កណិកា បានជាប់ពន្ធនាគារស្ទើរតែពាក់កណ្តាលនៃទោសអតិបរមាពីបទញុះញង់ ដែលជាប់ពន្ធនាគារច្រើនបំផុតនៃបទល្មើសនេះមានរយៈពេលពីរឆ្នាំ។ កញ្ញា ស កណិការ មិនមានវត្តមាននៅក្នុងសវនាការនោះទេ។



ព្រះតេជគុណ កើត សារ៉ាយ



ថា ឡាវី

## ខែកក្កដា ឆ្នាំ២០២១

**ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២១ – ការបន្តសវនាការលើក្រុមយុវជន** – បន្ទាប់ពីពន្យារពេលអស់រយៈពេលប្រាំខែដោយសារតែការរីករាលដាលជំងឺកូវីដ ១៩ សាលាដំបូងរាជធានីភ្នំពេញបានបន្តជំនុំជម្រះលើសមាជិកក្រុមយុវជនខ្មែរថាវរៈ។ លោក ថា ឡាវី កញ្ញា អេង ម៉ាឡៃ លោក មួង សុភ័ក្រ្ត និងព្រះតេជគុណ កើត សារ៉ាយ ត្រូវបានសួរដេញដោល ហើយពួកគេបានបដិសេធការចោទប្រកាន់ពីបទញុះញង់ ដោយអះអាងថាពួកគេគ្រាន់តែអនុវត្តសេរីភាពមូលដ្ឋានតាមរយៈការតវ៉ាទាមទារឱ្យដោះលែងលោក រ៉ុង ឈុន ប៉ុណ្ណោះ។ សាលាដំបូងរាជធានីភ្នំពេញនឹងបន្តសវនាការករណីនេះនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១។

**ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១ – ការបន្តសវនាការលើករណីកញ្ញា ស កណិការ** – សាលាដំបូងរាជធានីភ្នំពេញបានបើកសវនាការករណីកញ្ញា ស កណិការ។ តុលាការគ្រោងប្រកាសសាលក្រមនៅក្នុងខែសីហា ឆ្នាំ២០២១។





CC BY NC SA

ខែកក្កដា ឆ្នាំ២០២១

# ONE YEAR SINCE RONG CHHUN'S ARREST: A TIMELINE OF EVENTS



## WHO IS RONG CHHUN?

A prominent trade union leader and human rights activist. He is President of the Independent Cambodian Confederation of Unions, former president of the Cambodian Independent Teacher's Association, and a member of the Cambodia Watchdog Council.

### What are incitement charges?

Criminal charges under Articles 494 and 495 of the Cambodian Criminal Code for *"incitement to commit a felony or cause social unrest."* These charges carry a prison sentence of six months up to two years.

→ Incitement charges are frequently used against activists and human rights defenders for exercising their rights.

## July 2020

**20 July 2020** – Rong Chhun visited areas bordering Vietnam in Tboung Khmum province, where Cambodian farmers were prevented from cultivating their land because of new purported border demarcations. He later published a statement for the Cambodia Watchdog Council on irregularities in the border posts which allegedly resulted in the loss of hundreds of acres of Cambodian farmers' lands. The Government's Border Affairs Committee accused Rong Chhun of spreading false news.



**31 July 2020** – Rong Chhun gave a radio interview for RFA in which he denied spreading false information about the land loss at the border. He was later arrested without a warrant, late at night, with his home surrounded by 50 armed officers.

## August 2020

**1 August 2020** – Rong Chhun was charged with incitement. The reason for his arrest appeared to be his critical comments on the demarcation of the border between Cambodia and Vietnam. He was sent to pre-trial detention.

**26 August 2020** – The Court of Appeal refused to temporarily release Rong Chhun on bail, citing the potential danger that the trade unionist would repeat his statements.

## November 2020

**11 November 2020** – Rong Chhun testified before the Supreme Court that his detention was unlawful and filed another bail request to overturn his detention. He promised to cooperate with the Court and authorities upon release.



**25 November 2020** – The Supreme Court denied Rong Chhun's bail request under the justification of protecting "*security, public order, and the country's peace.*"

## January 2021

**15 January 2021** – The Phnom Penh Municipal Court began the trial into incitement charges against Rong Chhun. He denied the accusations of incitement and asserted he was exercising his freedom of expression to discuss an important issue.

## February 2021

**3 February 2021** – The Phnom Penh Municipal Court heard additional arguments into Rong Chhun's case. Rong Chhun stated he only visited the province of Tboung Khmum to help affected villagers and to monitor a land dispute. He also said that his comments were factual and not critical of the Government.

**17 February 2021** – A second hearing into Rong Chhun's case was held where Rong Chhun denied the incitement charges against him and claimed that his arrest was unjust due to the lack of an official arrest warrant.

## June 2021

**8 June 2021** – After spending more than 11 months in pre-trial detention, Rong Chhun was denied bail, despite an unprecedented COVID-19 outbreak in Cambodia's prisons. He has already served almost half of the maximum prison sentence for incitement charges which carry a prison sentence of up to two years. He was not present at the hearing.

## July 2021

**30 July 2021** – The Phnom Penh Municipal Court continued Rong Chhun's trial. A witness representing the Department of Border Affairs was present to provide some clarification on the case. The Court's verdict is expected to be announced in August 2021.


មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

@CCHRCambodia
@CCHRCambodia
cchrcambodia.org
sithi.org



CC BY NC SA



July 2021

# TIMELINE OF ACTIVISTS ARRESTED FOR PROTESTING FOR RONG CHHUN'S RELEASE



The arrest of Rong Chhun in July 2020 spurred a wave of protests across the country, with many youth activists gathering to call for his release from prison. Many protesters were consequently arrested and charged with incitement.



**What are incitement charges?**

Criminal charges under Articles 494 and 495 of the Cambodian Criminal Code for *"incitement to commit a felony or cause social unrest."* These charges carry a prison sentence of six months up to two years.

→ Incitement charges are frequently used against activists and human rights defenders for exercising their rights.



## August 2020

**4 August 2020 - Arrests of former CNRP activists**



After participating in protests calling for Rong Chhun's release, two former opposition party activists, Chhuor Pheng and Chum Puthy, were arrested in Phnom Penh. The activists attempted to meet monks, who had travelled from Battambang to join the protests in Phnom Penh but were stopped by the authorities on their way there. Both were later charged with incitement.

**7 August 2020 – Arrest of Sar Kanika** - Another former CNRP activist, Sar Kanika, was arrested after participating in protests calling for Rong Chhun's release. She was later charged with incitement and sent to pre-trial detention.

**13 August 2020 – Arrests of Chhoeun Daravy and Hun Vannak** -Two activists of the Khmer Thavrak youth group, Hun Vannak and Chhoeun Daravy, who had gathered in front of the Phnom Penh Municipal Court to demonstrate for Rong Chhun's release, were arrested. They were put in custody and charged a day later with incitement.

**14 August 2020 – Arrest of Soung Sophorn**

Soung Sophorn, President of the Khmer Win Party, was arrested after visiting the Tboung Khmum province to see the disputed Cambodia- Vietnam border area Rong Chhun had visited and after posting a video on Facebook in which he discussed purported border irregularities. Soung Sophorn had also participated in the widespread protests calling for Rong Chhun's release. Authorities claim that the information he disseminated about the border was incitement, which he was charged with the next day.

## September 2020

Sar Kanika



**3 September 2020 - Denial of bail for Sar Kanika** - The bail request of Sar Kanika was rejected by the Phnom Penh Municipal Court.

**6 September 2020 - Arrests of Koet Saray and Mean Prommony** - Venerable Koet Saray, an ordained Buddhist monk and member of Khmer Thavrak, and Mean Prommony, a Khmer Thavrak member and Khmer Student Intelligent League Association (KSILA) Vice President, were arrested for planning a peaceful assembly to call for Rong Chhun's release. The next day, both were charged with incitement and sent to pre-trial detention. Venerable Koet Saray was also defrocked.

**7 September 2020 - Arrests of Tha Lavy and So Metta/ Eng Malai** - Khmer Thavrak activists Tha Lavy and So Metta, also known as Eng Malai, were arrested and charged with incitement for demanding Rong Chhun's release. Tha Lavy was arrested while stepping out of a tuk-tuk at Phnom Penh's Freedom Park on his way to a peaceful demonstration for Rong Chhun. Eng Malai was arrested by authorities after leaving the office of the UN High Commissioner for Human Rights, where she had raised security concerns about authorities following her after she had left the protest at Freedom Park.



## October 2020

Moung Sopheak



**10 September 2020 – Arrest of Moung Sopheak** - Moung Sopheak, a KSILA member, was arrested for his participation in a peaceful protest calling for Rong Chhun's release several days prior. The next day, he was charged with incitement.

**2 October 2020 – Denial of bail for Sar Kanika upheld by the Appeal Court**

The Appeal Court upheld the Phnom Penh Municipal Court's decision of 3 September 2020 to deny bail to Sar Kanika.



Hun Vannak

Chhoeun Daravy



**20 October 2020 – Denial of bail by the Appeal Court for Hun Vannak and Chhoeun Daravy** - The Appeal Court denied bail to Hun Vannak and Chhoeun Daravy. The Court reasoned that it needed to further investigate their case and prevent the two from committing additional crimes.

## December 2020



**2 - 6 December 2020 – Prison violence against Eng Malai and Chhoeun Daravy**
Eng Malai and Chhoeun Daravy were allegedly beaten by inmates for going on a hunger strike from 2 – 6 December 2020 to request that prison officials respect the rights of political detainees. The Interior Ministry's Department of Prisons rejected the allegations: officials stated that Eng Malai was misbehaving and that other prisoners only tried to get her into the cell and that Chhoeun Daravy was not involved in the incident at all.



Eng Malai

**17 December 2020 – Rejection of request to stop investigations against Khmer Thavrak members** - The Appeal Court rejected a request to close the investigation into the seven Khmer Thavrak activists, citing incorrect filings related to the request.

**18 December 2020 – Denial of bail by the Appeal Court for members of Khmer Thavrak and KSILA** - Five activists, Eng Malai, Koet Saray and Tha Lavy from Khmer Thavrak, and Mean Prommony and Moung Sopheak from KSILA, were denied bail by the Court of Appeal, which said it wanted to ensure that the accused would attend their future trial hearings.



Mean Prommony

**30 December 2020 – Postponement of trial against youth activists** - The trial of youth activists and former CNRP members over their participation in protests calling for Rong Chhun's release was adjourned to summon police officials to verify the legitimacy of statements presented in the name of former CNRP activist Chhour Pheng. Chhour Pheng claimed that while parts of the statements were true, others were fabricated.

## January 2021

**12 January 2021 – Bail hearing at the Supreme Court for Sar Kanika** - The Supreme Court began hearing the bail appeal of Sar Kanika, who has been awaiting trial on charges of incitement.



**20 January 2021 – Denial of bail by the Supreme Court for Sar Kanika** - The Supreme Court denied bail to Sar Kanika.

## February 2021

**3 February 2021 – Continuation of trial of Sar Kanika** - The Phnom Penh Municipal Court heard further arguments in the case of Sar Kanika. She was questioned intensively about her relationship to Rong Chhun.



Soung Sophorn

**10 February 2021 – Prison sentence for Soung Sophorn** - Soung Sophorn was sentenced to 18 months in jail and fined more than $500,000 by the Phnom Penh Municipal Court. He was found guilty of incitement for purportedly distorting facts about the Cambodia-Vietnam border.

**16 February 2021 – Continuation of trial against youth activists** - The Phnom Penh Municipal Court continued the trial of Khmer Thavrak and KSILA members and CNRP activists. The Court scheduled to continue the trial of this case on 2 March 2021. It was then postponed.

**17 February 2021 – Continuation of trial of Sar Kanika** - Sar Kanika denied the incitement charge against her and claimed that police forged and edited communications between her and a friend to make it seem like she was guilty.

## May 2021

**18 May 2021 - Denial of bail for activists from Khmer Thavrak and KSILA** - After spending more than eight months in pre-trial detention, the Phnom Penh Municipal Court denied bail to seven activists: five members of Khmer Thavrak, Hun Vannak, Chhoeun Daravy, Tha Lavy, Koet Saray, Eng Malai, and two members of KSILA, Mean Prommony and Moung Sopheak. The Court's reasoning to deny bail was to ensure that the activists would be present for their trial, which has yet to be scheduled. The activists remain in pre-trial detention.

## June 2021

**8 June 2021 - Denial of bail for Sar Kanika** - After spending more than 11 months in pre-trial detention, Sar Kanika was denied bail, despite an unprecedented COVID-19 outbreak in Cambodia's prisons. She has already served almost half of the maximum prison sentence for the charge of incitement against her.




Koet Saray



Tha Lavy

## July 2021

**27 July 2021 – Resumption of trial against youth activists** - After being delayed for five months due to the COVID-19 pandemic, the Phnom Penh Municipal Court resumed the trial of youth activists from the Khmer Thavrak group. Tha Lavy, Eng Malai, Muong Sopheak and Koet Saray were questioned and denied the incitement charges, claiming that they were only exercising their fundamental freedoms by protesting for Rong Chhun's release. The next trial hearing was scheduled by for 31 August by the Court.

**30 July 2021 – Continuation of trial of Sar Kanika** - The Phnom Penh Municipal Court held a new hearing on Sar Kanika's case. The Court's verdict is expected to be announced in August 2021.



CC BY NC SA